# ការសម្ភាសរបស់លោកយាយ សួន ធូក

កៈ អ្នកធ្វើការសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកត្រូវគេសំភាសន៍ឈ្មោះ សួន ធូក

កៈ ជាដំបូងសូមជំរាបសួរម៉ា!!

ខៈ
ចាស!អាកាលពេលប្រវិត្តនឹងខ្ញុំដូចជាអត់បានដឹងទេហើយនឹងមិនចេះនិយាយអីនឹងទៀតនឹងដែលកាលពីសម័យមុននឹងមកនឹង។

កៈ
ចាសចឹងជាដំបូងនឹងខ្ញុំសូមចាប់ផ្តើមដើម្បីនឹងសួរទៅម៉ាសិនណាម៉ាណាចាំម៉ាធ្វើការនិយាយ។ចឹងកាសំភាសន៍ថ្ងៃនេះនឹងគេគ្រាន់តែចង់ក្រងឯសារសំរាប់អោយប្រជាជនកម្ពុជាយើងដែលគាត់មានប្រវិត្តពីមុខមកនឹងដើម្បីនឹងរក្សាវាទុកហើយដូចជាម៉ាជាក់ស្តែងនឹងដែលថាម៉ាបានធ្លាប់ចាំអីគេខ្លះចឹង។

ខៈ អូ!

កៈ ចាស!

ខៈ
យល់ហើយនឹងកាលនឹងវាមិនសូវជាបានចាំអីនឹងទេដូចថាជីវិតរបស់អ៊ុំនឹងដូចថាវារករៀនអីនឹងវាមិននេះទេព្រោះអីវាច្រើនជំនាន់មកហើយនឹង។

កៈ ចាសម៉ាកើតទាន់ច្រើនជំនាន់ហើយ។

ខៈ
នឹងព្រោះឥឡូវនឹងខ្ញុំវាបានជិត៩០ឆ្នាំទៅ៨០ឆ្នាំហើយវាច្រើនណាស់កាលពីជំនាន់របស់ខ្ញុំនឹងខ្ញុំបានភ្លេចអស់ទៅហើយវាមិនដឹងថាជាស្អីខ្លះនឹងទេ
ចាសហើយចឹងទៅខ្ញុំនឹងវាមិនបានដឹងថានឹងត្រូវជានិយាយវាអាម៉េចទេ។

កៈ ចាសត្រូវហើយម៉ា
ចាសចឹងបើសិនជាម៉ាបានភ្លេចចឹងម៉ាប្រាប់ថាម៉ាមិនបានចាំទៅណាម៉ាណា។

ខៈ នឹងហើយខ្ញុំភ្លេច។

កៈ ចាសចឹងជាដំបូងនឹងម៉ាមានឈ្មោះអ្វីដែរទៅម៉ា?

ខៈ ឈ្មោះខ្ញុំនឹងគឺ សួន ធូក នឹងហើយ។

កៈ ចាសហើយចឹងឈ្មោះម៉ាកាលនៅក្នុងអត្តសញ្ញាប័ណ្ណនឹងម៉ាមានឈ្មោះអ្វីគេដែល?

ខៈ ឈ្មោះខ្ញុំនឹងវាមានឈ្មោះចឹងដែលនឹងនៅក្នុងអត្តសញ្ញាប័ណ្ណនោះ។

កៈ ចាសចឹងវាល្អម៉េនទែនហើយចឹងម៉ាមានឈ្មោះសំរាប់នឹងហៅក្រៅដែលឬទេ?

ខៈ អត់ទេ!

កៈ អត់ទេចឹងណំ។

ខៈ ចាស!

កៈ ឈ្មោះនឹងនរណាគេដែលបានដាក់ឈ្មោះនឹងអោយដល់ម៉ា?

ខៈ ម្ដាយឪពុករបស់ខ្ញុំ។គាត់បានដាក់ឈ្មោះរបស់ខ្ញុំនឹងបានតាំងពីនៅតូចមកនឹង។

កៈ ចាសម៉ា!

ខៈ ចាសនឹងម្ដាយឪពុករបស់ខ្ញុំនឹងណាដែលគាត់បានដាក់ឈ្មោះនឹងអោយ។

កៈ
ចាសម៉ាហើយទៅកាលនឹងគាត់មានបានប្រាប់ឈ្មោះចឹងដោយសារតែមូលហេតុអ្វីដែលទៅម៉ា?

ខៈ អត់បានដឹងដែលកាលនឹងគាត់បើមិនបានដាក់ឈ្មោះនឹងអោយទេនឹងវាធ្វើម៉េចនឹងនេះហ៎។

កៈ ចាស១ម៉ាហើយម៉ាសព្វថ្ងៃនឹងម៉ាមានព្រះជន្មបានប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំនឹងមានអាយុបាន៧៩ឆ្នាំហើយ។

កៈ ចឹងអូម៉ាមានអាយុវែងហើយចឹងនោះ។

ខៈ
ចាសខ្ញុំនឹងវាបានកើតនឹងបានតាំងពីជំនាន់មុននឹងមកហើយចឹងខ្ញុំនឹងវាបានកើតឆ្លងកាត់នឹងមកវាបានច្រើនជំនាន់មកហើយថា តែវាបានភ្លេចចឹងណា។

កៈ ចាសត្រូវហើយម៉ា។

ខៈ ចឹងហើយនឹងស្មារតីនឹងវាអត់សូវជាបានចាំនោះទេ ។

កៈ ចាសហើយម៉ាសព្វថ្ងៃនឹងម៉ាមានអាយុបាន៧៩ឆ្នាំហើយចឹងម៉ាណ៎?

ខៈ ចាសមានអាយុ៧៩។

កៈ ចាសចឹងខ្វះ១ឆ្នាំទៀតនឹងម៉ាមានអាយុបាន៨០ឆ្នាំហើយចឹង។

ខៈ ចាស!

កៈ
ចាសហើយចឹងម៉ាសព្វថ្ងៃនឹងម៉ាមានបានចាំថាម៉ាមានបានកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរឬទេ?

ខៈ ហឹមិនបានដឹងថាឆ្នាំណានោះទេតែដឹងថាខ្ញុំនឹងបានកើតនៅក្នុងឆ្នាំរោង ខែផគ្រុបុត។

កៈ ចាស!

ខៈ ខែ១អីនឹងថ្ងៃអីនឹងខ្ញុំនឹងវាបានភ្លេចបាត់ទៅអស់ដែលនឹងខ្ញុំវាបានភ្លេចបាត់ទៅហើយណា។

កៈ ចាសម៉ាហើយម៉ាចឹងស្រុកកំណើតរបស់ម៉ានឹងនៅឯណាដែលទៅម៉ា?

ខៈ នៅឯនឹងតែម្តងនឹងនៅលើកោះនឹងចាសនៅនឹងកោះឧញ្ញាតីនឹងតែម្តងនឹង។

កៈ ចាស!

ខ៖ នឹងហើយ

ក៖ ចាសចឹងម៉ាមានទីលំនៅសព្វថ្ងៃនឹងក៏បាននៅនឹងដែរ?

ខ៖ ចាសក៏បាននៅនឹងដែរ។

ក៖ ចាស!

ខ៖ ចាស!

ក៖ ចាសហើយចឹងម៉ាមានកូនចៅបានប៉ុន្មាននាក់ដែរ?

ខ៖ ចាសកូនរបស់ខ្ញុំនឹងកាលនៅពីសង្គមនឹងខ្ញុំមានកូនចៅបាន៥នាក់ដែរ។

ក៖ហឺ!

ខ៖
តាំងខ្ញុំ១ទៀតនឹងវាបាន៦នាក់ហើយមានប្ដីរបស់ខ្ញុំនឹងបាន១នាក់ទៀតនឹងវាបាន៧នាក់ដែរនឹងតែដោយថាកាលនៅក្នុងជំនាន់អាពតនឹងគេបានធ្វើការជំលៀសខ្ញុំនឹងចេញទៅហើយគេបានអោយខ្ញុំនឹងទៅនៅនឹងខេត្តពោធិសាត់ចឹង។

ក៖ ចាស!

ខ៖
ហើយគេនឹងបានអោយខ្ញុំទៅយកកូននឹងបានយកប្ដីរបស់ខ្ញុំទាំងអស់នឹងទៅហើយបានទៅងាប់ទាំងអស់ទៅដោយសារកាលនឹងវាអត់មានអីស៊ី។

ក៖ ចាស!

ខ៖
ព្រោះអីកាលនឹងវាអត់មានបានបាយហូបចឹងណាកាលនឹងហើយវាបានអោយយើងបានហូបនឹងតែបបរ១កំប៉ុងនឹងវាមិនបានទៅរស់កាលនឹង។

ក៖ ចាសត្រូវ

ខ៖ ចាសចឹងហើយវាមិនអោយរស់នោះទេ

ក៖ ចាសម៉ា!

ខ៖
នឹងហើយងាប់អស់ទៅគ្រាន់តែប្តីរបស់ខ្ញុំនឹងប្តីរបស់ខ្ញុំនឹងបានស្លាប់ទៅអស់តែក្នុងរយៈពេល១ខែនោះទេកាលនឹងតែនៅក្នុងខែអស្សុជនឹង១ទេ។

ក៖ ហឺ!

ខ៖ កាលនឹងវាបានម្លូងតែថ្ងៃទេកាលនឹងនោះដែលខ្ញុំនឹងបានចាំណា។

ក៖ ហែ!

ខ៖ នឹងហើយនាង កាលនឹងកូនខ្ញុំនឹងបានស្រែប្រាប់ខ្ញុំណាថាម៉ែអើយខ្ញុំឃ្លានបាយណាស់ម្តាយអើយខ្ញុំឃ្លានបាយណាស់ បាយឆ្ងាញ់ណាស់ ។

ក៖ ហឺ!

ខ៖ ហើយទៅខ្ញុំនឹងក៏បានរកទៅវិញនឹងវាអត់បានកើត
នៅទេកាលនឹងនោះចឹងហើយបានថាខ្ញុំវាសព្វថ្ងៃនឹងវាចេះតែរាងហោយទៅចឹងណាហើយពេលខ្លះនឹងអាណាគេនឹងមកនឹងខ្ញុំចេះតែឆឹងទៅណា។

ក៖ ចាស់!

ខ៖
ចាសចឹងបានថានឹងកាលនឹងខ្ញុំនឹងវាដូចជាពេកវេទនាណាស់កាលនឹងចឹងបានថាខ្ញុំនឹងវាមិនចង់នឹងរំលឹកទេនឹងប៉ុន្មានពីនៃអីចឹងទៅខ្ញុំនឹងថាមិននឹងបានចាំអីនោះបានច្រើនទេ។

ក៖
ចាសម៉ាចឹងហើយខ្ញុំក៏សូមទោសចំពោះកន្លែងនឹងណាម៉ាដែលបានរំលឹកម៉ានូវរឿងរ៉ាវរបស់ម៉ាកាលពីមុនមកនឹងថាតើវាជួបនឹងយ៉ាងម៉េចខ្លះតែរឿងមួយនេះនឹងមិនមែនមានតែម៉ាម្នាក់ឯង

នោះទេព្រោះអីកាលនឹងអ្នកដែលមានវ័យប្រដៀងគ្នានឹងម៉ាហើយគាត់ក៏មានរឿងប្រដៀងគ្នាចឹងដែលនឹងម៉ា។

ខ៖ ចាស!

ក៖
ចឹងកាលនឹងពួកគាត់មានបានជួបនឹងកាលលំបាកនឹងដូចគ្នាទេចឹងហើយទៅគោលបំណងនៃកាលសំភាសន៍១នឹងគេបានមានគោលបំណងចង់អោយម៉ាបាននិយាយរឿងនៅក្នុងចិត្តនឹងមកដើម្បីអោយវាមានរាងធូរចិត្តហើយណាមួយទៀតនឹងគេក៏ចង់ក្រងប្រវិត្តរបស់ប្រជាជនកម្ពុជាដែលសំរាប់ទុកអោយកូនចៅជំនាន់ក្រោយទៀតនឹងកុំអោយវាបាត់បង់ណាម៉ាណា។

ខ៖ ចាសខ្ញុំយល់ហើយ។

ក៖ ចាស!

ខ៖ ចាសៗ

ក៖
ហើយចឹងដូចជាចៅទួតនឹងចៅលួតរបស់ម៉ាដែលគេបានស្តាប់សំលេងម៉ា១នឹងចឹងហើយគេអាចនឹងបានដឹងថាអូ!នេះគឺជាម៉ារបស់ខ្ញុំនឹងគាត់បាននិយាយអំពីប្រវិត្តរបស់គាត់កាលពីដើមមកនឹងហើយចឹងកាលនឹងគាត់មានប្រវិត្តជូជត់ចេក!

ខ៖ ចាស!

ក៖
អូចឹងគេបានថាអូកាលនឹងម៉ារបស់ខ្ញុំនឹងគាត់គឺជានារីដែលអស្ចារ្យមែនទែនដែលបានខំប្រឹងមកដើម្បីនឹងធ្វើការតស៊ូរហូតមកដល់ពេលថ្ងៃនេះណាម៉ាណា។

ខ៖ ចាសកូនខ្ញុំនឹងវានៅនឹងវាអាបងគេនឹង អាយុគេប្រហែលជាចង់៥០ឆ្នាំហើយ
ប្រហែលជា៥០លើសហើយ។

ក៖ ចាស!

ខ៖ នឹងហើយ។

ក៖ ចាសចឹងសព្វថ្ងៃនឹងម៉ាមានកូនទាំងអស់នឹងបានប៉ុន្មានាក់ដែរ?

ខ៖ ខ្ញុំមានកូនទាំងអស់នឹងមានប្រហែលជាបាន៥នាក់ណា។

ក៖ ហើយកូនស្រីបានប៉ុន្មាននាក់ដែលម៉ា?

ខ៖ កូនស្រី២ប្រុស៣នាក់។

ក៖ គាត់មានឈ្មោះអ្វីខ្លះទៅម៉ា?

ខ៖ ចាសគេមួយនឹងមានឈ្មោះអាទី១នឹងឈ្មោះថាណែកអា សាមិធិក មចាន់ណារា បានមកនឹង សមាលីហើយបានមកនឹង ភារម្យ អានឹងមីងស្រី។

ក៖ ចាស!

ខ៖ ចាសបាន៥នាក់នឹង។

ក៖ ហើយចុះស្វាមីរបស់ម៉ានឹងគាត់មានឈ្មោះអ្វីដែរ?លោកតា?

ខ៖ លោកតា ងួន ម៉ន។

ក៖
ចាសហើយកាលនឹងលោកតានឹងលោកយាយនឹងគាត់បានស្រលាញ់គ្នានឹងដោយចិត្តនឹងចិត្ត ឬក៏អីដែរ?

ខ៖
ហឺកាលនឹងឪពុកម្តាយរបស់ខ្ញុំនឹងគាត់បានរៀបចំអាពាហ៍ពិពាហ៍អោយខ្ញុំនឹងបានយ៉ាងល្អណាស់លោកអោយ។

ក៖ ចាស!

ខ៖ នឹងហើយ

ក៖ ហើយចឹងកាលនឹងម៉ាបានរៀបការនៅក្នុងឆ្នាំណាដែរ?

ខ៖ ហឹកាលនឹងខ្ញុំនឹងវាបានភ្លេចទៅទាំងឆ្នាំអីនឹងទៀត។

ក៖ ចាសចឹងក៏កាលនឹងនៅក្នុងជំនាន់ណាដែល?

ខ៖
កាលនឹងពីសម័យសង្គមនឹងតែម្តងខ្ញុំបានដឹងតែបានការនឹងបានតាំងពីសង្គមនឹងណាកាលនៅក្នុងជំនាន់របស់ខ្ញុំនោះនឹងណា។

ក៖ ចាស!

ខ៖
ចាសហើយកាលនឹងផ្ទះនឹងធ្វើហើយនឹងពេលដែលការខ្ញុំនឹងចឹងហើយផ្ទះនឹងមានអាយុបានជាង៥០ឆ្នាំហើយព្រោះអីពេលនឹងបានធ្វើផ្ទះនឹងហើយនឹងបានខ្ញុំការតែម្តង។

ក៖ អូបានយូរហើយ។

ខ៖
ហើយអានឹងខ្ញុំវាបានចាំថាចឹងឯងបើថាអោយខ្ញុំនឹងទៅនិយាយរឿងឆ្នាំខែអីនឹងខ្ញុំនិយាយមិនចេញនោះទេ។

ក៖ ចាសៗ

ខ៖ ចឹងបើនិយាយចឹងខ្ញុំវានិយាយអត់ចេញនោះទេ។

ក៖ ចាសអូហើយចឹងផ្ទះនេះមានអាយុបានជិត៥០ហើយចឹង
ចឹងផ្ទះនេះមិនបាននឹងធ្វើការផ្លាស់ប្តូរអីទេណុំម៉ាណុំ?

ខ៖ អត់ទេមិនបានផ្លាស់ប្តូរនោះទេ
ហើយចឹងផ្ទះនឹងវាមានអាយុបានជាង៥០ឆ្នាំជាងហើយនឹងវាបានជាង៥០ឆ្នាំហើយនឹងពេលនឹងបានជាខ្ញុំនឹងបាននៅចាំនឹងដោយសារតែកាលនឹងវាបានកាលដែលការខ្លួនរបស់ខ្ញុំនឹងណាស់។

ក៖ ចាស!

ខ៖ ហើយពេលនឹងបានធ្វើហើយនឹងបានរៀបការខ្ញុំតែម្តងនឹង។

ក៖ ចាស

ខ៖ នឹងហើយ។

ក៖ ចាស

ខ៖ នឹងហើយកាលនឹងខ្ញុំនឹងបានចាំតែចឹងនោះទេ។

ក៖ ចាសចឹងកាលនឹងផ្ទះនឹងបានកសាងឡើងនឹងដោយការជួលគេឬក៏បានទៅជួលគេចឹងម៉ា?

ខ៖ កាលនឹងបានជួលគេខ្លះចឹងទៅក៏បានធ្វើខ្លួនឯងអីនឹងខ្លះចឹងទៅ។

ក៖ អូ!

ខ៖
ចឹងកាលនឹងនោះលោកឪពុករបស់ខ្ញុំទេណាដែលគាត់បានធ្វើនឹងនោះមិនមែនជាខ្ញុំទេណាចឹងឪពុកខ្ញុំទេដែលគាត់ជាអ្នកធ្វើនឹងព្រោះអីកាលនឹងខ្ញុំនឹងវារាងនៅតូចៗដែរទេកាលនឹងនោះវាមិននៅនេះទេ។

ក៖ ចាសចឹងកាលនឹងផ្ទះនឹងបានធ្វើនៅក្នុងម៉ូតអីដែរកាលនឹងម៉ា?

ខ៖ កាលនឹងបានធ្វើនឹងជាម៉ូតផ្ទះ ប៉ិត អានឹងណា។

ក៖ អូចឹងផ្ទះប៉ិននឹងវាស្អាតចឹងណាម៉ា។

ខ៖ កាលនុងណាម៉ាជុំនឹងមានតែផ្ទះរបស់ខ្ញុំទេកាលនឹងដែលវារាងបានលោភជាងគេនឹងនោះតែឥឡូវនឹងវារាង

ក៖ ចាសឥឡូវនឹងគេបានឡើងធ្វើផ្ទះថ្មៗ

ខ៖ ចាសនឹងគេនឹងគេបានធ្វើផ្ទះថ្មអស់ហើយ។

ក៖ ចាសប៉ុន្មានផ្ទះនេះជាកេរ្តិ៍ដំណែលម៉ា។

ខ៖
ចាសជាកេរ្តិ៍ដំណែលជារបស់កេរ្តិ៍ដំណែលដែលបានបន្សល់ទុកមកដល់ឥឡូវនឹងចឹងហើយ
នេះនឹងវារបស់កេរ្តិ៍ឪខ្ញុំហើយនឹង។

ក៖
ហើយចឹងកាលនឹងការសាងសងផ្ទះនឹងបានធ្វើឡើងនឹងបានចំណាយលុយអស់ប៉ុន្មានដែរទៅ
ម៉ាឬក៏មានបានចំណាយនោះទេ?

ខ៖ ហឺ
អត់មានថាអត់នោះទេកាលនឹងដូចជាវាអស់ដែលតើនាងតែកាលនឹងវាមិនបានដឹងថានឹងវាអ
ស់ជាប៉ុន្មានចឹងព្រោះអីខ្ញុំនឹងវាមិនបានដឹងនោះទេព្រោះអីកាលនឹងឈើនឹងវាក៏បានថោកហើ
យចំណែកឯឈើនឹងវិញនឹងក៏វារាងថ្លៃដែរចឹងណាស់។ នឹងហើយ

ក៖ កាលនឹងយើងបាននឹងទិញឈើគេដែលដ៏ម៉ានែល។

ខ៖
ចាសបានទិញគេមកតើកាលនឹងព្រោះអីកាលនឹងគេបានយកមកចកនៅក្នុងជិតនៅកន្លែងជិត
នៅកំពង់ទឹកយើងនឹងមកម៉េចចឹងទៅណា
ចាសហើយចឹងកាលនៅក្នុងសម័យកាលពីជំនាន់ដើមនឹងកាលនឹងវាមិនទាន់ជាមានអីណាដូច
ជាឥឡូវនោះទេព្រោះអីកាលនឹងគេបាននាំគ្នានឹងទៅដងទឹកនឹងជាមួយនឹងក្អមនឹងយកមកដា
ក់នៅក្នុងពាងចឹងទៅកាលនឹងនោះ!

ក៖ ចាសម៉ាចឹងត្រូវហើយកាលនឹងនោះ
ហើយកាលនឹងលោកឪពុកនឹងអ្នកម្តាយរបស់ម៉ានឹងតើគាត់មានឈ្មោះអ្វីគេខ្លះដែរ?

ខ៖ គាត់មានឈ្មោះដូចគ្នានឹងម្តាយរបស់ខ្ញុំនឹងគាត់មានឈ្មោះថាសួន
ហើយម្តាយរបស់ខ្ញុំនឹងគាត់ក៏មានឈ្មោះថាសួននឹងដូចគ្នាដែរនឹងចាស។

ក៖
ចុះចំណែកឯនាមត្រកូលរបស់ពួកគាត់ទាំង២វិញ?តើនាមត្រកូលរបស់គាត់នឹងមានឈ្មោះដូច
គ្នាដែរឬទេ?

ខ៖ ចាសមួយមានឈ្មោះថា ឆាយ សួនហើយមួយទៀតនឹងមានឈ្មោះថាស្វាយ សួន។

ក៖ ចាស!

ខ៖ នឹងហើយ

ក៖
ចាសហើយចុះពួកគាត់ទាំងអស់គ្នានឹងតើពួកគាត់មានទីលំនៅឯណាដែលសំរាប់ពួកគាត់ទាំង២នាក់នឹង?

ខ៖ អឺឪពុករបស់ខ្ញុំនឹងគាត់មានទីលំនៅនៅខាងឯព្រៃឈរងនោះ
នៅក្នុងស្រុកដែលគេបានហៅថាសែកយំចឹងណាហើយចំណែកក្នុងស្រុកនឹងផ្ទាល់គឺមានទីតាំងនៅក្នុងខេត្តកំពង់ចាមយើងនោះអឺ។

ក៖ ចាស!

ខ៖ នឹងហើយ

ក៖ ចំណែកឪពុកម្តាយរបស់ខ្ញុំនឹងគាត់មានទីលំនៅនៅនឹងក្នុងភូមិនឹងតែម្តងនឹង។

ខ៖
ចាសចឹងកាលនឹងស្រុកកំណើតរបស់ម៉ានៅក្នុងទីនេះហើយចំណែកឯឥឡូវនឹងម៉ាក៏មានស្រុកទីនេះដែរ?

ក៖ ចាស!

ខ៖គាត់មាននៅទីនេះដែរនឹង។

ក៖ ចុះម៉ាមានបងនឹងប្អូនចំនួនប៉ុន្មាននាក់?

ខ៖ បងប្អូនរបស់ខ្ញុំនឹងពួកគាត់បានស្លាប់អស់ហើយ។

ក៖ តើពួកគាត់មានឈ្មោះអ្វីខ្លះទៅម៉ា?

ខ៖ អីកូនទី១នឹងគេមានឈ្មោះថាឡុនយី ហើយនឹងនាង វ៉ាន ហើយប្អូនយ៉ង ប្អូនម៉ុន ហើយនឹងមិនបានដឹងជាមាននរណាគេទៀតទេនេះ។ ខ្ញុំបានភ្លេចបាត់ទៅហើយ។ ហើយចឹងកាលនឹងវាមានបានមក១១ខ្ញុំនឹងបងយីនមួយនាក់ទៀត។

ក៖ ចាស!

ខ៖ នឹងហើយ

ក៖ ចាស!

ខ៖ អស់ហើយ

ក៖
អូចឹងសោកស្តាយណាស់ចឹង។ហើយចឹងបងប្អូនរបស់ម៉ានឹងមានស្រីប៉ុន្មាននាក់ហើយប្រុសមានប៉ុន្មាននាក់ដែរ?

ខ៖ មានប្រុសតែ១នាក់គត់តែអូមានប្រុសចំនួន២នាក់ប្រុសនឹង

ក៖ អូប្រុសចំនួន២!

ខ៖ កូនទី៣នឹងទី៥។

ក៖ ហើយចុះកាលនឹងម៉ាមានអាយុបានប៉ុន្មានឆ្នាំហើយ?

ខ៖ កាលនឹងខ្ញុំប្រហែលជានៅអាយុខ្ទង់អើយ....

ក៖ ជាង៣០ឆ្នាំហើយ?

ខ៖ អើយ!

ក៖ កាលនឹងនៅក្នុងជំនាន់អាពតម៉ា!

ខ៖ ហាស!

ក៖ កាលម៉ានៅក្នុងជំនាន់អាពតនឹងម៉ាមានអាយុបានប៉ុន្មានឆ្នាំហើយ?

ខ៖ កាលនៅក្នុងជំនាន់ពពតនឹងខ្ញុំមានអាយុនឹងវាបានខ្ទង់៥០អីហើយ

ក៖ ចាស!

ខ៖ ចាស!

ក៖
ចុះបងប្អូនរបស់ម៉ាកាលនៅក្នុងជំនាន់អាពតនឹងបានស្លាប់ទៅនឹងវាស្លាប់ទៅទាំងអស់គ្នាតែម្តង?

ខ៖ ចាសបានស្លាប់ទៅនឹងទាំងអស់គ្នាតែម្តងស្លាប់ទៅនឹងអាលីង។

ក៖ ចុះលោកយាយនឹងលោកតាដែរត្រូវជាឪពុកម្តាយរបស់ម៉ាវិញ?

ខ៖
កាលចំណែកឯឪពុកម្តាយរបស់ខ្ញុំនឹងគាត់ទាំង២បានស្លាប់ទៅនឹងមុនសម័យអាពតនោះទេកាលនឹងនឹងហើយប៉ុន្តែនឹងបងៗរបស់ខ្ញុំនឹងពួកគាត់បានស្លាប់នឹងក្នុងអាពតទាំងអស់នឹងហើយ។

ក៖ ទាំងស្វាមីដែរ?

ខ៖ នឹងហើយគឺទាំងអស់តែម្តងទាំងប្តីខ្ញុំទាំងអីនឹង។

ក៖ ចាស ហើយកាលនឹងគេមិនបាននឹងជំលៀសនោះទេ?

ខ៖ ចាសអត់ទេគេមិនបានជំលៀសនោះទេនៅតែក្នុងនឹង។

ក៖ ចាសហើយចឹងចុះម៉ានឹងក្រុមគ្រួសារគឺនៅជាមួយនឹងគ្នា?

ខ៖ អត់នោះទេកាលនឹងគេបានធ្វើការជំលៀសចេញ
កាលនឹងគេបានជំលៀសពួកគាត់ចេះចឹងទៅហើយក៏ឪពុករបស់ខ្ញុំនឹងគាត់ស្លាប់នៅនឹងនឹងនោះទេអត់មានស្លាប់នៅនឹងឯណានោះទេអានឹងវាក្នុងសម័យស្រុកនឹងវានៅសានគ្រានទេណា ។

ក៖ ចាស!

ខ៖
ហើយក៏បានដល់ពេលផុតពីជំនាន់របស់ឪពុករបស់ខ្ញុំទៅនឹងកាលនឹងឪពុករបស់ខ្ញុំនឹងគាត់បានទាន់នៅក្នុងសម័យអាពតនឹងដែលតែគេបានធ្វើការជំលៀស ។

ក៖ ចាស!

ខ៖ គេបានធ្វើការជំលៀសនឹងទៅនៅនឹងឯសំលូតនឹងជាមួយនឹងខ្ញុំទៅណា
ហើយចឹងទៅពេលនឹងគាត់បានឈឺគាត់ចេះតែឈឺហើយគាត់ចេះតែថាកូនអើយយកឪទៅផ្ទះ
ហើយចំណែកខ្ញុំកាលនឹងមានណា
ខ្ញុំនឹងគេមិនបាននឹងអោយខ្ញុំនឹងនឹងទៅឯណានោះទេកាលនឹង។

ក៖ អូ!

ខ៖ នឹងហើយ គេមិនអោយយើងនឹងទៅណា។

ក៖ ចឹងកាលនឹងបើគេមិនអោយម៉ាទៅណាចឹងម៉ាមិនអត់សុខហើយ?

ខ៖
ហ៊ឺកាលនឹងវាអត់សុខនឹងហើយពេលឈឺអីនឹងគេបានអោយថ្នាំយើងដែរតែវាជាប្រភេទថ្នាំគ្រាប់ដូចអាចម៍ទន្សាយដែលសំរាប់នឹងមើលជំងឺអោយយើងនឹងរាងរបស់វានឹងរាងតូចៗហើយខ្មៅៗហើយគេបានយកមកអោយយើងនឹងលេប។

ក៖ ហ៊ឺចឹងកាលនឹងគាត់បានលេបបាត់ដែរឬទេម៉ា?

ខ៖ ហ៊ឺមានអីកាលនឹងគាត់មានបាននឹងលេបអីណាគាត់បានស្លាប់ទៅនឹងបណ្តោយទៅ។

ក៖ចាស!

ខ៖ កាលនឹងគាត់បានស្រែករកផឹកទឹកដោះគោតែកាលនឹងមានឯណាទៅនាងអើយចឹង។

ក៖ ចាស!

ខ៖
ដល់ពេលហើយទៅពេលឪពុករបស់ខ្ញុំគាត់បានស្លាប់ទៅបាត់ចឹងគេបានយសពរបស់ឪពុកខ្ញុំនឹ

ង
យកអីនឹងដែលកាលនឹងគេបានអោយយកសពគាត់នឹងយកមកផ្ទះនឹងតែកាលនឹងឆ្អឹងរបស់គាត់នឹងមិនបានដឹងថាពេលនឹងគេបានយកឆ្អឹងរបស់គាត់នឹងទៅក្រវេញចោលទៅឯណានោះទេកាលនឹងវាអត់បានដឹងដែរនឹងដល់ពេលរួចហើយនឹងបានដឹង។
ហើយកាលនឹងគេបានធ្វើការជំលៀសខ្ញុំនឹងទៅដល់ខេត្តពោធិសាត់ទៀត ។

ក៖ ហឺ!

ខ៖
ខ្ញុំនឹងគេបានជំលៀសនឹង២ទៅ៣កន្លែងឯនោះកាលនឹងខ្ញុំគេបានជំលៀសពីកោះឧញ្ញាតីនឹងហើយនឹងក៏គេបានធ្វើការជំលៀសទៅខាងឯនោះខាងឯវិហារសួនយើងនឹងណា។

ក៖ចាសម៉ា!

ខ៖ នឹងហើយ
គេបានអោយទៅនៅនឹងសារុងព្រះវិហារសួរនឹងកាលនឹងគាត់បានអោយបានប៉ុន្មាននោះទេកាលនឹងគេបានឡើងកាប៉ាលនឹងកាណូតទៅ

ក៖ គេអោយបានធ្វើដំណើរតទៅទៀត។

ខ៖
នឹងកាលនឹងគេបានអោយធ្វើដំណើរនឹងអោយតទៅទៀតហើយគេនឹងបានអោយទៅនៅឯនឹងយើងណែកនៅឯរថភ្លើងនឹងឯនៃក
នៅឯស្អីគេនេះនឹងវាបានភ្លេចបាត់ទៅហើយកាលនឹងចឹងហើយបានជាគេនឹងបានអោយខ្ញុំនឹងឡើងរថភ្លើងនឹងបានទៅទៀត។

ក៖ ហឺ!

ខ៖នឹងហើយរួចបានទៅដល់នឹងហើយនឹងគេបានអោយនឹងដាក់យើងនឹងនៅក្នុងរទេះគោនៅឯកន្លែងនឹងកាលនឹង។

ក៖ ចាសចុះកាលនឹងហេតុអ្វីបានជាគេធ្វើការជំលៀសម៉ានឹងបានជាច្រើនដងចឹង?

ខ៖ នឹងម៉េចទេកាលនឹងនរណាទៅដឹងគេក្អួយអើយ!

ក៖ ចុះកាលនឹងឪពុកម្ដាយអីនឹងកាលនឹងម៉ាមានមុខរបរជាអ្វីដែរម៉ាមានមុខរបរធ្វើអ្វីដែរ?

ខ៖ កាលនឹងខ្ញុំគ្មានបានទៅធ្វើអីទេកាលនឹងខ្ញុំគ្រាន់តែជាអ្នកត្បាញ់នឹងរវៃនឹងជាធម្មតានឹង។ ហើយកាលនឹងចំណែកប្ដីរបស់ខ្ញុំវិញនឹងបានជាគាត់ជាអ្នកដែរបានធ្វើការនឹងហើយ។

ក៖ កាលនឹងគាត់មានមុខរបរជាអ្វីដែរទៅម៉ា?

ខ៖
ហ្វយកាលនឹងគាត់នឹងបានត្រឹមធ្វើការងារជាអ្នកដែរបើកសំពលឡាននឹងណាកាលនឹងសំរាប់នឹងបើកអីនឹងសំរាប់តែនឹងធ្វើការចិញ្ចឹមជីវិតបានតែបន្តិចបន្ទួចនឹងបានខ្លះចឹង
តែការនឹងគាត់បានធ្វើការងារនឹងនៅក្នុងរដ្ឋណាកាលនឹងនោះ។

ក៖ ចាសហឺ
កាលនឹងគេបានជំលៀសម៉ាទៅជាច្រើនកន្លែងចឹងគេបានប្រើម៉ាអោយទៅធ្វើអ្វីគេខ្លះទៅកាលនឹង?

ខ៖
ហឺកាលនឹងវាអោយយើងនឹងធ្វើនឹងកាលនឹងវា...ធ្វើអោយខ្ញុំនឹងមិនចង់នឹងនិយាយនោះទេកាលនឹងបើនឹកឃើញទៅនឹងខ្ញុំចង់តែស្រកទឹកភ្នែកនឹងទេ
កាលនឹងវាវេទនាណាស់នាងអើយកាលនឹងវាអោយយើងនឹងស៊ីអីមិនឆ្អែកហើយនឹងវាប្រើកាលនឹងម៉ានឹងជាប់គុកទៀតនឹងណាកាលនឹងខ្ញុំបានជាប់គុកកាលនៅក្នុងសម័យអាពតនឹងអារឿងស្រូវអង្កនឹងវាមិនទៅខ្លះអីនោះទេកាលនឹងវារើសតែស្រូវស្រែនឹងក៏វាស៊ីមិនទៅអស់ដែល តែកាលនឹងគេមិនអោយយើងនឹងទៅរើសទៀតនឹងហើយ។ គេមិនអោយយើងរើសទេ។

ក៖ ហឺកាលនឹងស្ដោយណាស់ វាសុខចិត្តអោយយើងនឹងអត់ចឹងណាម៉ាណេស?
វានឹងអាក្រក់តែម្ដងនឹង។

ខ៖
កាលនឹងវាសុខចិត្តអោយយើងនឹងអត់កាលនឹងវាយកពួកយើងនឹងទៅហើយកាលនឹងណាបើថាពេលដែលវាបានយកពួកយើងនឹងទៅហើយនឹង

វាអាចនឹងវៃចោលទៅនឹងភ្លាមៗនឹងវាមិនទៅកើតនឹងចឹងហើយបានជាវានឹងធ្វើបាបចឹងដោយការបង្អត់គ្រប់អង្គរនឹងចឹង អានឹងវាចឹងឯចាស។
នឹងហើយអង្ករ១កំប៉ុងអីនឹងបានបបរ១ខ្ទះនៅចឹងហើយអង្គបាន២ទៅ៣គ្រាប់នឹងហើយចំណែកឯបន្លែអីនឹងបានជាគេនឹងបានស៊ីនឹងដូច...កាលនឹងថាសត្វជ្រូកទៅវាស៊ីចឹងហើយកាលនឹងវាធ្វើអោយស៊ីនឹងអោយដូចទៅនឹងកាលនឹងវាជាងសត្វជ្រូកទៀតនឹងកាលនឹងថៅអើយវារកអីនឹងទៅប្រៀបធៀបមិនបាននោះទេថៅអើយ។

កៈ ចាសហើយចឹងកាលនឹងគេបានធ្វើបាបយើងនឹងច្រើនពេក។

ខៈ នឹងហើយវាហួយហើយ

កៈ ហើយចឹងកាលនឹងម៉ាគេបានធ្វើបាបម៉ាដូចជាមានធ្លាប់វៃម៉ាដែរឬទេ?

ខៈ ធ្លាប់កាលនឹងគេបានធ្លាប់វៃ
ដែលកាលនឹងនោះឥឡូវនឹងខ្ញុំនឹងវាមិនចង់នឹងនិយាយអីនោះទេកាលនឹងខ្ញុំនឹងវាបានឆ្អែកណាស់ មុននឹងបានរស់នឹងវារស់បានដោយវេទនានឹងហើយផលរបស់ខ្ញុំនោះទេនឹងហើយកាលនឹងដើរទៅទាក់នឹងខ្សែតែប៉ុណ្ណឹងទេកាលនឹងក៏ម៉ានឹងដួលដែលកាលនឹងហើយកាលនឹងវាថាស្គមនោះស្គមបើមើលទៅរូបរិញនឹងវាមិនដូចស្អីនោះទេកាលនឹងវាវេទនាណាស់ម្ចាស់ថ្លៃអើយកាលនឹងវាវេទនាណាស់។

កៈ ចាសកាលនឹងវាបានធ្វើបាបម៉ាចឹងហើយចុះគេផ្សេងៗទៀត
តើពួកគាត់ទៅជាមួយនឹងម៉ាចឹងគាត់ចឹងដែរ?

ខៈ ដូចគ្នានឹងកាលនឹងពួកគេនឹងបានងាប់អស់
អាបងប្អូនដែលបានជំលៀសទៅទាំងប៉ុន្មានៗនឹងអាខ្លះទៅណឹងបានគេយកទៅសំលាប់ចោលនឹងដាច់ពូជទៅម៉ាតៗៗអស់អាលីងៗៗតែម្តងនៅតែរោងទទេទេ។

កៈ ហឺ!

ខៈ អារោងដែរបានធ្វើសំរាប់នឹងអោយយើងនៅនឹងណា។

កៈ ចាស!

ខ៖ ចាសនឹងហើយ

ក៖ ចាសចឹងកាលនឹងម៉ាមានសំណាងម៉ែនទែន កាលនឹងបានម៉ាតស៊ូបានមករួច!

ខ៖
ចាសបានតស៊ូមករួចនឹងកាលនឹងខ្ញុំនឹងវាមិនបាននឹងស្មមថាថាខ្ញុំនឹងបានប៉ុណ្ណឹងនោះទេនាង
អើយ។

ក៖ ការនឹងគេផ្សេងៗទៀតនឹងគេបានតស៊ូដូចម៉ាផង?

ខ៖ មានកាលនឹងមានគេយកកូនទៅនឹងមានគេនៅរស់ខ្លះចឹងដែរ?

ក៖
អូកាលនឹងអ្នកដែលបានគេជំលៀសទៅជាមួយនឹងម៉ានឹងមានគេបាននៅរស់ចឹងដែរណាំម៉ាណាំ
?

ខ៖ មានគេនៅរស់
ណែកាលនឹងគេបានទៅនឹងគេធ្វើការជំលៀសនឹងទៅជាមួយនឹងគ្នាប៉ុន្មាននឹងគេបានអោយ
ទៅធ្វើការនៅក្រុមខុសគ្នាចឹងណា។

ក៖ ចាស!

ខ៖ មួយគេនៅឯជើងចឹងទៅហើយមួយទៅគេបាននៅនឹងខាងត្បូងចឹងទៅចឹង
ហើយមួយនៅឯលិចចឹងទៅណានៅឯខេត្តនឹងវាខុសៗគ្នា។

ក៖ ចាស!

ខ៖
វានៅខុសៗគ្នានឹងប៉ុន្តែកាលនឹងវាមានដោយកន្លែងទេកាលនឹងវាមាននៅកន្លែងខ្លះចឹងទៅក៏
វារាងស្រួលទៅហើយកន្លែងខ្លះទៅក៏គេបានធ្វើការរឹតបន្តឹងទៅ។

ក៖ ចាស!

ខ៖ ហើយកាលនឹងបើមិនស្រួលនឹងមិនបានរស់នោះទេ។

ក៖ចាសត្រូវហើយម៉ាចឹងកាលនឹងវាលំបាកខ្លាំងមែនទែនកាលនឹង
ហើយចឹងកាលនឹងម៉ាបានចង់ចាំទិន្នភាពអីគេខ្លះដែរធ្វើអោយម៉ាបាននឹងឃើញមក
ដូចជាកាលនឹងគេបាននឹងធ្លាប់ធ្វើអ្វីនៅក្នុងសម័យនឹងដែលធ្វើអោយម៉ាមានការចង់ចាំជាងគេ
?

ខ៖
កាលនឹងមានធ្វើអីកាលនឹងគេបានអោយម៉ានឹងបានទៅស្ទូងស្រូវនឹងចឹងហើយកាលនឹងបាន
ជាម៉ានឹងគេបានធ្វើអីនឹងក៏ម៉ាទៅធ្វើ
គេអោយទៅរែកអីចឹងហើយគេបានអោយទៅរែកាស់អីចឹងនោះ។

ក៖ ចាស!

ខ៖ កាលនឹងវាចេះតែប្រើយើងហើយ។

ក៖ ចឹងកាលនឹងគេបានចេះប្រើម៉ារហូតចឹង?

ខ៖ គេនឹងបានប្រើយើងនឹងទៅរហូតនឹង។

ក៖ ចឹងកាលនឹងគេបានអោយម៉ាធ្វើការប៉ុន្មានម៉ោង?

ខ៖
កាលនឹងមិនបានដឹងថាដំម៉ោងម៉ាអីម៉ានោះទេកាលនឹងខ្ញុំនឹងតែកាប់ទៅអោយវានឹងអោយហើ
យ។

ក៖ ចាសនឹងតែហើយ។

ខ៖ ហើយកាលនឹងវាមានក្រចៃលវានឹងអោយតែដល់ពេលម៉ោង៣យប់នឹងវាដើរហៅគេហើយ
កាលនឹងវានៅម៉ោង៣អីនឹងវាមិនទាន់នឹងភ្លឺចឹងណាកាលនឹង
វាមានការដើរហៅនឹងអោយទៅឯសមរភូមិវាងនឹងកាលនឹងម៉ោង៣អីនឹងត្រូវក្រោកទៅហើយ
។

ក៖ ហើយដល់ពេលព្រឹកឡើងអឺកាលនឹងពេលដល់ល្ងាចបានចូលផ្ទះ?

ខ៖ អត់ទេកាលនឹងបើនៅឯណានឹងនៅនឹងហើយ កាលនឹងគ្មានទៅបានចូលទេ

ក៖ អុស!

ខ៖ កាលនឹងដូចថាថៅឯព្រឹកចឹង
ដូចថាបានអោយយាយនឹងព្រឹកនឹងហើយយាយនឹងទៅធ្វើការងារនៅឯនេះចឹងហាំ
ថានៅឯចំការនៅឯផ្ទះនោះចុះ ចឹងនិយាយត្រឹមផ្ទះនឹងចុះអោយបានជិត
ហើយដល់ពេលដែលបានទៅចឹងទៅក៏ទៅនឹង។

ក៖
ចាសចឹងកាលនឹងពេលដែលបានទៅធ្វើការងារនឹងហើយនឹងទៅនៅកន្លែងនឹងតែម្តង?ហើយកាលនឹងចំពោះឯទឹកភ្លើងនឹងខោអាវអីនឹងធ្វើយ៉ាងម៉េចទៅកាលនឹងយើងធ្វើកាលស្តាយយកទៅតែម្តង?

ខ៖
ខោអាវនឹងខ្ញុំប្រាប់ទៅណាកាលនឹងពេលដែលខ្ញុំនឹងវាមិនទាន់នឹងបានជាប់នៅក្នុងគុកចឹងគ្រាន់បាន បានទឹកអីនឹងបានមុជទឹកចឹងណា។

ក៖ ចាស!

ខ៖
ចឹងកាលនឹងទាល់តែវានឹងបានអោយយើងទៅនឹងបានបានមិនសិនជាវានិងមិនអោយទៅទេគឺអត់។ហើយចំណែកឯខោអាវវិញនឹងគឺបានកើតជាចៃនៅក្នុងខ្លួននឹង
កាលនឹងចៃនឹងវានៅក្នុងសំពត់របស់យើងនឹង។

ក៖ ចាសចឹងកាលនឹងដោយសារតែកាលនឹងយើងខានងូតទឹកយូរណែម៉ាណែ?

ខ៖
ហឺកាលនឹងមិនបាននឹងថាកាលនឹងវាមានទឹកនឹងនៅកន្លែងណាទេថៅអើយកាលនឹងនោះថៅអើយៗកាលនឹងយើងបានដើរទៅនឹងសមរភូមិវានឹងវាវេទនាណាស់។

ក៖ ហឺ!

ខ៖
កាលនឹងម៉ាណាចយើងនឹងវាស្រែកទឹកនឹងពេលដែលបានឃើញអាអន្លង់គោនោះកាលនឹងយាយនឹងបានដាច់ចិត្តថាមិនទៅខ្ពើមមិនអីនោះទេកាលនឹងព្រោះវាស្រែកណាស់។

ក៖ ចាស!

ខ៖
ហើយដល់ពេលដែលយកមាត់យើងនឹងទៅហឹតទឹកនឹងនឹងទៅកាលនឹងមានឈ្លឹងនឹងវាទៀមអីយវាវេទនាណាស់ចៅ
បានថាចៅអើយកុំសួរយាយទៀតយាយហត់ណាស់បើនិយាយនឹងនិយាយវាមិនទៅអស់នោះទេ។

ក៖ ចាសៗ

ខ៖
កាលនឹងបើនិយាយនឹងប៉ុន្មាននឹងក៏វានឹងមិនទៅអស់ដែលជីវៈប្រវត្តិនឹងនោះអាប្រវត្តិអាពតនឹងនោះខ្ញុំវាមិនចង់នឹងនិយាយទេ។

ក៖ ចាស!

ខ៖ ចាសចឹងបានហើយតែប៉ុណ្ណឹងចុះ!

ក៖ ចាសអរគុណច្រើនម៉ាសំរាប់នឹងការសំភាសន៍ហើយអើយ
ឥឡូវនឹងអត់សួរទៅរឿងនៅជំនាន់អាពតទៀតនោះទេថាវាបិតនៅត្រង់នឹងតែម្តងទៅណាម៉ា!

ខ៖ អឹម!

ក៖
ចឹងសួរពីក្តីស្រមៃរបស់ម៉ាវិញថាកាលដែលពេលម៉ានៅពីក្មេងនឹងនៅពីតូចមកនឹងថាពេលនឹងម៉ាមានបាននឹងធ្លាប់ស្រម៉ៃចង់ធ្វើអ្វីដែរឬទេម៉ា?

ខ៖ អត់ទេកាលនឹងគ្មានទេ គ្មានដែរនឹងចង់ធ្វើអីនោះទេចៅ
កាលនឹងដឹងតែ១ស្រុករខ្ញុំនឹងគ្មាននរណាគេចេះនឹងចង់ថានឹងទៅធ្វើជាស្អីៗនឹងគឺថាអត់ទេកា

លនឹងដឹងតែពី
កាលនឹងធ្វើចំការហើយដល់ពេលព្រលឹមឡើងចឹងទៅបានដាក់ត្បាញ់ទៅកាលនឹងបើថាដល់ពេលខែដាក់ដាំទៅនឹងបានដាំទៅ។

ក៖ ចាស!

ខ៖ នឹងហើយ

ក៖ ចាសចឹងជីវិត...

ខ៖
នឹងហើយកាលនឹងពេលដែលបានមកពីចំការវិញនឹងបានដាក់ដាំបាយអីចឹងទៅហើយគេបានដាក់ការត្បាញ់ចឹងទៅកាលនឹងនៅក្រោមផ្ទះនឹងតែប៉ុណ្ណឹងនោះទេ។

ក៖ ចាសកាលនឹងជិវិតពេលនឹងវារាងសាមាញ ធម្មតាហើយសម្បាយចិត្តណាម៉ាណំ។

ខ៖ ចាសធម្មតាចាស

ក៖ មិនដូចជាពេលនឹងវាត្រូវគិតច្រើន ហា
ហើយឥឡូវនឹងគិតច្រើនថាពេលរៀនហើយនឹងត្រូវទៅធ្វើអ្វីចាស។

ខ៖ កាលជំនាន់នឹង កាលនឹងនៅជំនាន់ម៉ានឹងអត់មាននរណាគេដែលបានចេះអក្សរនោះទេ។

ការនឹងមិនមានអីរៀននោះទេកាលនឹងអត់មានទេថៅ។

ក៖ ហឺសចឹងអត់សូវជាបានគិតច្រើនទេចឹង។

ខ៖
អត់មានទេកាលនឹងនោះអត់មានដែលបាននឹងគិតថាពេលដែលអញនឹងបានរៀនចប់ហើយនឹងតើអញនឹងត្រូវទៅរៀននៅឯណា ទៅរៀននៅឯនោះអីចឹងអត់នោះទេ។

ក៖ ហឺសៗៗ

ខ៖ អត់ទេកាលនឹងអត់មានទេ!

កៈ
ចាសហើយចឹងកាលនឹងម៉ាជំនាន់នឹងមកម៉ាអត់មានបានចូលសាលាអីសំរាប់រៀននឹងក៏អត់បានចូលដែរម៉ាណេស?

ខៈ ខ្ញុំ ដូចជាអត់ទេ។

កៈ
ចុះចឹងម៉ាមានបានចេះនឹងធ្វើការអានអក្សរអីនឹងបានដាច់ដែរឬទេចឹង?ដូចជាមានអក្សរបាលីនឹងអក្សរបស់លោកអី?

ខៈ អត់មានទេចៅនឹង។

កៈ ចាស!

ខៈ និយាយរួមទៅនឹងថាអត់តែម្តងទៅ!

កៈ ចាសហើយចុះម៉ាមានបងនឹងប្អូននៅបរទេសដែលឬទេ?

ខៈ អត់ទេ!

កៈ នៅស្រុកក្រៅអីនឹងក៏អត់មានដែរម៉ា?

ខៈ អត់មានទេបើមានអីនឹងក៏ខ្ញុំនឹងមិនទៅនឹងនេះដែរ
កាលនឹងមកនឹងដល់ពេលសព្វថ្ងៃនឹងបាននៅនឹងជាមួយនឹងមីប្អូននឹងហើយគេនឹងត្រឹមតែមកនឹងដែលនឹង។
ខ្ញុំនឹងបាននៅនឹងតែខ្ញុំនោះទេបាននៅនឹងជាង៣០ឆ្នាំហើយបាននៅនឹងតែម្នាក់ឯងដែលបានមកពីអាពតវិញនឹង។

កៈ ហឺ!

ខៈ ខ្ញុំបានមកនៅនឹងជាងបាន៣០ឆ្នាំហើយ។

កៈ អូម៉ា ម៉ាមានមុខរបរជាអ្វីដែរសព្វថ្ងៃនឹង?

ខ៖
ម៉ាអត់មានអីទេសព្វថ្ងៃនឹងចៅអើយមានតែកំប៉ិតកំប៉ុននឹងចឹងកាលនឹងវាបានរស់នឹងបាននៅនឹងផលនឹងហើយកាលនឹងពេលដែលគេបានមកនឹងហើយចឹងគេបាន
ជូនលុយអីគេបានជូនកាក់អីនឹងបានបន្តិចបន្តួចអីចឹងទៅហើយក៏បាននឹងឆ្លៀតសំរាប់យកទៅធ្វើបុណ្យទៅ
ខ្លះយកសំរាប់ស៊ីអីចឹងទៅហើយខ្លះទៀតនឹងយកទៅសំរាប់នឹងធ្វើការមើលខ្លួនអីចឹងទៅ។

ក៖ ចាស!

ខ៖ ចឹងខ្លះទៅម៉ាមិនទៅត្អូញត្អែរប្រាប់ដល់ចៅទេម៉ានឹងវាខ្មាស់ណាស់ចឹងៗអីនោះចៅ។

ក៖ ចាស!

ខ៖ ចាស!

ក៖អូចឹងគេបានជូនបុណ្យអោយម៉ាអីនឹងក្នុង១ថ្ងៃ
ដូចជាខែបុណ្យទានអីនឹងមានបងប្អូនគេបានមកលេងមកអីចឹងមកទៅគេបានឃើញម៉ាចឹងគេបានជូនម៉ាទៅ!

ខ៖ចាសគេបានឃើញចឹងគេក៏បានជូនទៅនឹងហើយ!

ក៖ ចាស!

ខ៖ មាននឹងនៅក្នុងខែបុណ្យភ្ជុំរដូវ បុណ្យអីនឹងដែលបានជូនលុយអីចឹងទៅណា។

ក៖ ចាសគេបានជូនម៉ាសំរាប់នឹងទុកធ្វើបុណ្យអីចឹងទៅនឹងសំរាប់អីទៀតចឹងទៅ?

ខ៖ ចាសនឹងហើយសំរាប់នឹងយកទៅធ្វើបុណ្យនឹង
នឹងសំរាប់យកទៅស៊ីអីចឹងខ្លះទៅ។វាមិនមែននឹងរកដូចនឹងកំលាំងអីនឹងយើងនោះទេថាចង់ទិញអីក៏ទិញចឹងទៅនោះណា ហើយចង់ស៊ីអីចឹងក៏ស៊ីអីចឹងវាមិនដូចទេ។

កៈ ចាសត្រូវហើយ ចាស ហើយចុះខ្ញុំឃើញថានៅខាងក្រោយនឹងមានដាំជាចំការចេកម៉ាណោសចុះចំការនឹងម៉ាជាអ្នកដាំណំម៉ាណោស?ហើយក៏..

ខៈ ចេកម៉ាបានដាំនៅពេលដែលម៉ាមានកាលដែលម៉ានឹងនៅមានកំលាំងនៅឡើយនោះ។

(សំលេងសត្វចាបយំ)

កៈចាសឥឡូវនឹងបានផលហើយ។ហោសៗៗ

ខៈ បានផលហើយនឹងប៉ុន្តែនឹងវាបានយូរៗបាន១ស្ទង់នឹងនឹងបានផលម្តងនឹងវាមិនទៅស៊ីអីនឹងទៅគ្រាន់នោះទេ។(មានសំលេងសត្តចាបយំ ជិបៗៗៗៗ)

កៈ ដូចជាដីនៅខាងក្រោយនឹងនៅឆ្ងាយទៀតទេម៉ាឬក៏នៅឆ្ងាយទៀតទេម៉ា?

ខៈ ដីនឹងគេបានអោយនឹងតែបន្តិចនឹងគេអោយតែប៉ុណ្ណឹងតែមួយក្រវិតនឹង។

កៈ ម៉ាមានដីនោះសល់ច្រើនកន្លែងដែរឬទេ?

ខៈ មានដីនៅសលនឹងបាននៅច្រើនកន្លែងតែគេមិនបាននឹងអោយ។

កៈ គេបានចែកអោយម៉ាតែប៉ុណ្ណឹង។

ខៈ គេបានចែកអោយក្នុង១ភូមិនឹង។គេបានថាអោយយើងនឹងថាអត់មានកូន។

កៈ អឺក៏ប៉ុន្តែ

ខៈ កាលនឹងគេបានថាអោយយើងនឹងថាយើងនឹងវាអត់មានកូន។

កៈ ហ៊ើចឹងក៏មានដីច្រើនជាងនឹងដែរម៉ាណែស?

ខៈ ដីនឹងណាបើថានិយាយពីរឿងដីកេរ្តិ៍នឹងកាលនឹងដីរបស់ខ្ញុំនឹងវាមាននឹងនៅដល់ដីនៅឯកោះឯណោះ។

កៈ ចាសហើយនៅខាងក្រោយនឹងមានមាត់ទឹក?

ខៈ មានមាត់ទឹកនឹងនៅខាងក្រោយដីនឹងដែរនឹង វាជាដីទន្លេណា។

ក,ៈ ហើយឥឡូវនឹងដីនៅនឹងម្តងនឹងវារាងថ្លៃណាស់នឹង។

ខៈ នឹងហើយឥឡូវនឹងវាមានដីនឹងឡើងថ្លៃណាស់នៅម៉ុំនឹងនោះ
ហើយទៅបើថានឹងមានដីឯណានឹងលក់ទៅនឹងដូចគេដែលនឹងវាគ្មានបានដីអីសំរាប់នឹងលក់ទៀតនឹង
វាមានតែដីនៅបានបន្តិចនឹងសំរាប់នឹងទុកនឹងកប់ខ្លួនរបស់ឯងនឹងនៅពេលដែលសំរាប់នឹងស្លាប់នឹង។

កៈ ចាសហើយចឹងទៅម៉ាមានបទពិសោធន៍ល្អៗនៅក្នុងជីវិតរបស់ម៉ាដែរឬទេ?
ដូចជាពេលដែលម៉ាបាននឹងនឹកឃើញឡើងនឹងវាបានធ្វើអោយម៉ាបានសប្បាយចិត្ត។

ខៈ
មានសព្វថ្ងៃនឹងម៉ាមានតែនឹងធ្វើការនឹកឃើញអ្វីនោះទេម៉ាមានតែមានរឿងណាដែលធ្វើអោយម៉ានឹងនឹកឡើងនឹងសប្បាយចិត្តអីនឹងវាគ្មាននោះទេ ។
ចឹងមានតែពេលដែលនឹងទៅមុននឹងមានតែផ្លូវដែលស្លាប់ទៅនឹងវាបាននឹកឃើញហើយនឹងវាបានធ្វើអោយយើងនឹងឡើងវេទនាមានតែប៉ុណ្ណឹងនោះទេវាគ្មានបាននឹងនឹកឃើញឡើងនឹងទៅសប្បាយអីនឹងវាមិនបានទៅនឹកឃើញនោះទេមានតែម៉ងនឹងឯង។
អត់មានថានឹកឃើញហឺហាអីនឹងវាគឺអត់នោះទេ
ហើយបើថាពេលដែលមានលុយទៅនឹងអោយខ្ញុំនឹងយកទៅធ្វើបុណ្យដើម្បីនឹងធ្វើការឧទិកសលអោយទៅវិញចឹង។

កៈ
ចាសពេលដែលម៉ាមានការធ្វើបុណ្យអីចឹងទៅវាបាននឹងជួយម៉ាអោយបានសប្បាយចិត្តដែរចឹង។

ខៈ
ចាសខ្ញុំនឹងធ្វើការធ្វើបុណ្យនឹងដើម្បីនឹងអោយទៅដល់ឪពុកម្តាយជីតាបងប្អូននឹងកូនក្មួយនឹង

ដែលបានស្លាប់ទៅនឹងទាំងប៉ុន្មាននឹងអោយបានផលនឹងជួយទៅឃឹតយោងកុំអោយមានកម្ម ពាលហើយអោយតែមានក្តីសុខអោយទៅកាន់ទីបរមសុខទៅកុំអោយជួបនឹងប្រទេសជាតិនឹង វាមានអកុសលនឹងចឹងទៀត។

ក៖ ចាសម៉ា

ខ៖ ចាសខ្ញុំមានតែប៉ុណ្ណឹងនោះទេ។

ក៖ ចាសម៉ាម៉ាជាស្រ្តីដែលរឹងមាំមែនទែនហើយម៉ាមានការតស៊ូមកនឹងរហូត។
ហើយក៏សង្ឃឹមដែលថាពេលដែលគេបានស្លាប់សំលេងរបស់ម៉ានឹងហើយយកម៉ាធ្វើជាគំរូកុំអោយចុះចាញ់
កុំអោយអីតែរឹងមុាំដូចជាម៉ាចឹងដែលបានខំប្រឹងរហូតមកនឹងហើយម៉ានឹងបានរកត្រូវដូចជាពេលដែលម៉ាបានទំនេរអីនឹងមករហូតមកម៉ានឹងមានការធ្វើបុណ្យអីនឹងដើម្បីសាងបុណ្យកុសលទៀតចឹងទៅណាម៉ា។

ខ៖
ចាសនឹងហើយមានតែប៉ុណ្ណឹងនោះទេ។ចាសយាយនឹងមានតែប៉ុណ្ណឹងនោះទេចៅយាយអត់មានអីនោះទេ។

ក៖ ចាស!

ខ៖ ហើយថាអោយយាយនឹងទៅធ្វើការងារអីនឹងឥឡូវនឹងក៏មិនកើតដែលឥឡូវនឹងនោះ។

ក៖ ចាសត្រឹមត្រូវហើយម៉ា ហើយម៉ាចូលចិត្តស្តាប់បទចម្រៀងដែរឬទេម៉ា?

ខ៖ អូអត់ទេ!

ក៖ កាលពីដើមឡើយនឹងណា!

ខ៖ អូកាលពីដើមមកឡើយនឹងម៉ាចូលចិត្តស្តាប់ការពីនេះមកនឹងដូចថាម៉ានេះមកនឹង!!!

ក៖ ហឺ!!

ខ៖
ហើយកាលនឹងកាលនៅពីដើមមកនឹងម៉ាចូលចិត្តតែដល់ពេលឥឡូវនឹងម៉ាចូលចិត្តស្ដាប់បទចម្រៀងអីនឹងម៉ាចូលចិត្ត។

ក៖ ចាសហើយកាលនឹងបទចម្រៀងអីគេដែលដែលម៉ាចូលចិត្តស្ដាប់?

ខ៖ ហែសកាលនឹងមិនបានដឹងថាបទអីបទអីនោះទេកាលនឹងនោះ
ចៅអើយកាលនឹងយាយមិនបានទៅជាចាំនោះទេកាលនឹងនោះ។

ក៖ ចាសកាលនឹងមានដូចជាលោកតា ស៊ុន ស៊ីសាតនោះ!

ខ៖
ចាសនឹងហើយចៅអើយកាលនឹងដូចថាពេលនឹងចៅនឹងយាយនឹងបានស្ដាប់ខ្លះចឹងទៅកាលនឹងនោះមិនថាអត់បាននឹងស្ដាប់សោះនោះទេ។

ក៖ ចាស!

ខ៖ កាលនឹងយាយនឹងបានស្ដាប់បានខ្លះ!

ក៖
ចាសហើយចុះម៉ាកាលនឹងដូចជាល្បែងអីនោះកាលនឹងដូចជានៅឯក្មេងៗនឹងតើម៉ាចូលចិត្តលេងអីគេខ្លះ?

ខ៖ កាលនឹងពេលដែលនៅក្មេងៗនឹងម៉ានឹងដូចចិត្តលេងនឹងមានដូចបោះអង្គុញអី!

ក៖ ចាសកាលនឹងមានដូចជាល្បែងទាញព្រ័នអីនឹងខ្លះចឹងទៅកាលនឹងនោះ។

ខ៖ ចាស!

ក៖ ចាសចឹងកាលនឹងសប្បាយ!

ខ៖
នឹងហើយកាលនឹងមានតែប៉ុណ្ណឹងនោះទេកាលនឹងនោះពេលនឹងយាយមិនបានដឹងថានឹងមាន

អីនោះទេកាលនឹងតែយាយកាលនឹងបើថាអោយទៅរាំវង់អីនឹងយាយមិនចេះរាំអីនោះទេ។ ចាសកាលនឹងនៅមួយស្រុករបស់ម៉ានឹងវាមិនមានគេទៅផ្លើតផ្លើននោះទេ។

ក៖ ហឺ!

ខ៖ ទេ!

ក៖ ចាសកាលនឹងនោះបានខ្លាចឪពុកម្ដាយ?

ខ៖
ចាសខ្លាចឪពុកម្ដាយ!ទៅណាមកណាអីនឹងកាលនឹងមានគេបុណ្យទានអីចឹងហើយកាលនឹងមានគេជួលអីនឹងកាលនឹងមិនបានហ៊ាននឹងទៅដើរមើលនោះទេកាលនឹងនោះព្រោះអីកាលនឹងខ្លាចគេនឹងចាប់។

ក៖ ចាសកាលនឹងមានគេនេះដែលម៉ាដូចជាអសន្តិសុខ?

ខ៖
មានឯណាកាលនឹងនោះកាលនៅជំនាន់នឹងមានការនៅខ្សត់ខ្សោយវាមិនមានដូចនៅជំនាន់ឥឡូវនឹងឯណា!

ក៖
ចាសហើយចឹងកាលនឹងមានដូចជាពេលនឹងបើសិនជាគេនឹងបានដើរលេងយប់ៗអីនឹងមានខ្លាចគេនឹងចាប់?

ខ៖ ចាសខ្លាចគេ
កាលនឹងខ្លាចគេនឹងផ្ចាបាយើងណាកាលនឹងខ្លាចគេនឹងធ្វើបាបយើងនឹងចោលទៅណាកាលនឹងចាសស្ដាប់បានដែរឬទេ?

ក៖ចាស!

ខ៖
ចាសអានឹងយើងចេះតែខ្លាចចឹងទៅកាលនឹងវានឹងនៅមិនទាន់នឹងធ្វើបាបអីយើងនោះទេប៉ុន្តែ

កាលនឹងនោះយើងនឹងនៅតែខ្លាចហើយកាលនឹងម្ដាយឪពុកយើងនឹងក៏គាត់មិនទៅបណ្ដោយអោយយើងនឹងធ្វើអ្វីដែលព្រោះគាត់នឹងចេះតែខ្លាចៗចឹងណា

ក៖ ចាសចឹងកាលនឹងត្រូវហើយម៉ានៅកាលនឹងនោះ
ហើយចឹងម៉ានៅជាចុងក្រោយនឹងតើម៉ាមានជាពាក្យពេជ្រអ្វីនឹងសំរាប់នឹងអោយមកនឹងហើយចឹងតើម៉ានឹងមានពាក្យពេជ្យអ្វីដែលនឹងសំរាប់ធ្វើការផ្ដាំផ្ញើរដល់ម៉ាចឹងណា!

ខ៖
ឥឡូវនឹងបើយើងនិយាយទៅនឹងគេមិនទៅស្ដាប់យើងនោះទេព្រោះអីគេថាអោយយើងនឹងចាស់កំរិល ចឹងហើយនឹងខ្ជិលផ្ដាំផ្ញើរណាស់ចឹងហើយខ្ជិលនឹងផ្ដាំណាស់តែប៉ុណ្ណឹងចុះ!

ក៖
ចាសចឹងសូមអរគុណដល់ម៉ាដែលបានធ្វើការចំណាយពេលសំរាប់កាលសំភាសន៍១នេះសង្ឃឹមការសំភាសន៍១នេះនឹងជួយដល់ម៉ានៅក្នុងការដូចជានិយាយរឿងពិតហើយនឹងម៉ានឹងអាចអោយនឹអឺដូចជាម៉ាមានមោទណភាពសំរាប់ខ្លួនឯងដែលម៉ាជាមនុស្សម្នាក់ដែលបានភ្លាប់បានជួបនឹងកាលលំបាកមែនទែននៅក្នុងសម័យនោះ
ដែលម៉ាបានតស៊ូនឹងមានជីវិតរស់ពីជំនាន់នឹងមកដែលខណៈពេលដែលមានប្រជាជនខ្មែរយើងនឹងច្រើនដែលកាលនឹងដែលពួកគាត់បានឆ្លងកាត់ហើយពួកគាត់និងមិនបានមានជីវិតរស់ដូចម៉ាផង
ហើយម៉ាជាស្ត្រីដែលអស្ចារ្យដែលបានខំប្រឹងតស៊ូចិញ្ចឹមកូនហើយម៉ាចាសហើយឥឡូវនឹងម៉ាមានអាយុបាន៧៩ឆ្នាំហើយម៉ាមានបទពិសោធន៏ច្រើនមកនឹងហើយចឹងខ្ញុំសូមសរសើរម៉ាមែនទែន!

ខ៖ ចាស!

ក៖ ចាសអរគុណច្រើនម៉ា!

ខ៖ អឺម!